ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទៅៈ មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម
មកដល់, ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦
លេខ ១៤៣
ម៉ោង ព្រឹក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤២៣៧ កសក

# សេចក្តីណែនាំស្តីពី
# វិធានការជំរុញការងារបង្កបង្កើនផលស្រូវរដូវវស្សា ឆ្នាំ២០១៦

ភ្លៀងបានចាប់ផ្តើមធ្លាក់ជាបណ្តើរៗនៅគ្រប់តំបន់ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូលបន្ទាប់ពីព្រះរាជពិធីច្រត់ព្រះនង្គ័លដែលជាសញ្ញាបង្ហាញថា រដូវវស្សាបានឈានចូលមកដល់ហើយ។ ជាមួយគ្នានេះ ប្រជាកសិករបានចាប់ផ្តើមបង្កបង្កើនផលស្រូវរដូវវស្សានៅតាមតំបន់ដែលមានទឹកគ្រប់គ្រាន់ដោយសម្រេចបានចំនួន ១៤៧ ៧៣០ ហិកតា នៃផែនការ ២ ៤៧៤ ៤៤៦ហ.ត គិតត្រឹមថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦។

ក្នុងគោលបំណងជំរុញផលិតកម្មស្រូវវស្សាឱ្យសម្រេចបានតាមផែនការយ៉ាងតិច ៧លានតោន នៅឆ្នាំ ២០១៦នេះ និងដើម្បីបង្កើនផលិតកម្មស្រូវនិងការនាំចេញអង្ករឱ្យមានសន្ទុះកើនឡើងថែមទៀត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់អង្គភាពក្រោមឱវាទនិងមន្ទីរកសិកម្មរាជធានី ខេត្តទាំងអស់ ឱ្យយកចិត្តទុកដាក់ជំរុញផលិតកម្មស្រូវវស្សាតាមរយៈការផ្តល់អនុសាសន៍ដល់ប្រជាកសិករអនុវត្តផលិតកម្មដំណាំស្រូវតាមលក្ខណៈប្រពលវប្បកម្មឱ្យមានប្រសិទ្ធភាពនិងប្រសិទ្ធផលខ្ពស់ ដោយពិចារណាទៅលើយន្តការនិងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗ ដូចខាងក្រោមៈ

១- ត្រូវរៀបចំមធ្យោបាយផលិតកម្មរួមមាន កម្លាំងអូសទាញជាសត្វពាហនៈ គ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្មគ្រប់ប្រភេទ ដើម្បីចាប់ផ្តើមភ្ជួរដាស់ដីនិងកៀរពង្រាបស្រែឱ្យបានល្អត្រៀមសម្រាប់ធ្វើការដាំដុះ ដោយអនុវត្តតាមគោលការណ៍ "ភ្ជួរឱ្យប្រសើរ កៀរដីឱ្យស្មើ រាស់ឱ្យបានម៉ដ្ឋ"។

២- ត្រូវរៀបចំប្រព័ន្ធភ្លឺនិងប្រឡាយបញ្ចេញបញ្ចូលទឹកឱ្យបានត្រឹមត្រូវទៅតាមស្ថានភាពដីស្រែក្នុងតំបន់ ដើម្បីធានាការគ្រប់គ្រងទឹកឱ្យមានប្រសិទ្ធភាពសម្រាប់ដំណាំស្រូវ ព្រមទាំងជីកស្តារស្រះ ប្រឡាយ អាងស្តុកទឹក រក្សាទឹកទុកបង្ការការខ្វះខាតនៅចុងរដូវ ដោយអនុវត្តតាមគោលការណ៍ "ផ្តល់ទឹកគ្រប់គ្រាន់ តម្រូវបន្ទាន់ តាមដំណាក់កាល"។

៣- ត្រូវចុះណែនាំបច្ចេកទេសកសិកម្មសមស្របដល់ប្រជាកសិករនិងត្រូវត្រៀមជាស្រេចនូវគ្រាប់ពូជស្រូវដែលមានភាពសុទ្ធល្អ មានដំណុះខ្ពស់ និងមានសុខភាពល្អ សម្រាប់យកទៅធ្វើការដាំដុះ ដោយប្រើកម្រិតគ្រាប់ពូជឱ្យសមស្របទៅតាមប្រភេទពូជ និងវិធីសាស្ត្រដាំដុះ (ព្រោះដោយដៃ ប្រើឧបករណ៍អូសដាំ និងស្ទូង)។ ម្យ៉ាងទៀត ត្រូវសម្អាតគ្រាប់ពូជឱ្យបានស្អាត ដោយយកគ្រាប់ស្មៅចេញឱ្យអស់ និងសម្លាប់មេរោគនៅលើគ្រាប់ពូជមុនពេលយកទៅដាំ ដើម្បីចៀសវាងការដុះស្មៅច្រើន និងកើតជំងឺនៅក្នុងស្រែ ដោយអនុវត្តតាមគោលការណ៍ "ប្រើគ្រាប់ពូជសុទ្ធ ជ្រើសរើសហ្មត់ចត់ មានគុណភាពខ្ពស់"។

៤- ត្រូវប្រមូលជីធម្មជាតិរួមមាន ជីលាមកសត្វ ជីកំប៉ុស្ត ជីពីឡជីវឧស្ម័ន យកទៅដាក់ស្រែជាជីទ្រាប់បាត រួចធ្វើការភ្ជួរលប់ឱ្យបានល្អ ដើម្បីទប់ស្កាត់ការបាត់បង់សារធាតុចិញ្ចឹម ជាពិសេសការបំភាយសារធាតុអាសូត "N" ទៅក្នុងបរិយាកាស។ ត្រូវពិនិត្យឱ្យអស់លទ្ធភាពលើការប្រើប្រាស់ជីធម្មជាតិនិងការប្រើប្រាស់ថ្នាំកសិកម្មដែលលាយផ្សំដោយធាតុផ្សំធម្មជាតិដែលអាចរកបាន និងមានស្រាប់នៅក្នុងមូលដ្ឋានដើម្បីកាត់បន្ថយការចំណាយដោយអនុវត្តតាមគោលការណ៍ "**គ្រប់គ្រងជីជាតិ យកជីធម្មជាតិជាមូលដ្ឋានគ្រឹះ**"។

៥- ត្រូវស្វែងរកទីតាំងសមស្របនៅក្បែរប្រភពទឹកសម្រាប់ធ្វើថ្នាលសំណាប ហើយត្រូវរៀបចំថ្នាលសំណាបតាមបទដ្ឋានបច្ចេកទេស ដើម្បីផលិតសំណាបបានល្អដោយអនុវត្តគោលការណ៍ "**សាបលើថ្នាលគោក ជីមានមមោក សំណាបថ្លោសល្អ**"។

៦- ចំពោះដំណាំស្រូវដែលបានដាំដុះរួច ត្រូវណែនាំកសិករចុះពិនិត្យមើលថែទាំនិងការពារដំណាំឱ្យបានជិតដល់ជាប្រចាំ ពោលគឺ កម្ចាត់ស្មៅឱ្យបានល្អ រក្សាទឹកឱ្យបានគ្រប់គ្រាន់ និងពិនិត្យមើលស្ថានភាពនៃការបំផ្លាញរបស់សត្វចង្រៃ និងជំងឺ ជាពិសេសសត្វទ្រីបនិងជំងឺអុចត្នោតដែលតែងតែកើតឡើងនៅដំណាក់កាលសំណាបក្នុងលក្ខខណ្ឌរាំងស្ងួត ដោយចាត់វិធានការកម្ចាត់ឱ្យទាន់ពេលវេលា។

ទទួលបានសេចក្តីណែនាំនេះ ប្រធានអង្គភាពក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវសហការឱ្យបានល្អជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ សំដៅចូលរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករឱ្យទទួលបានជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

វេង សាខុន

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងផែនការ

-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងធនធានទឹកនិងឧតុនិយម

-ក្រសួងអភិវឌ្ឍន៍ជនបទ

-ក្រសួងព័ត៌មាន

-ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

-អាជ្ញាធរជាតិគ្រប់គ្រងគ្រោះមហន្តរាយ

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-គ្រប់សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"

-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-គ្រប់មន្ទីរកសិកម្មរាជធានី-ខេត្ត

"ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ